ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៦.៥ ...... សហវ.ប្រក.អន្តរ

អង្គភាពប្រឆាំងអំពើពុករលួយ
ចូល លេខ ២១៦/២០២៤ ......
ថ្ងៃទី០៦.០២.២៤ ម៉ោង ០៩.៣០'

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការប្រែក្លាយ និងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការនិងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ស្តីពីឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណី តាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៤២៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការពិន័យជាប្រាក់ និងការដាក់ទណ្ឌកម្មលើយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បានឃើញប្រកាសអន្តរក្រសួងលេខ១៨៣ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ នីតិសម្បទានជានគរបាលយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១ .-**

ការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចផ្លូវថ្នល់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**ប្រការ២ .-**

ការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ ត្រូវបានរៀបចំជាបញ្ជីផាកពិន័យ ដែលមានរាយលម្អិតអំពីប្រភេទបទល្មើស និងកម្រិតទឹកប្រាក់ផាកពិន័យ ទៅតាមស្ថានទម្ងន់នៃប្រភេទបទល្មើសនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣ .-**

ការផាកពិន័យដែលកំណត់ដោយប្រកាសអន្តរក្រសួងនេះ មិនរួមបញ្ចូលការផាកពិន័យលើការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់អតិបរមា ដែលចែងក្នុងច្បាប់ស្តីពីផ្លូវថ្នល់ ឡើយ។

**ប្រការ៤ .-**

ចំណូលប្រមូលបានពីការផាកពិន័យ និងការផ្តន្ទាទោសពិន័យជាប្រាក់ ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីផ្លូវថ្នល់ ត្រូវកត់ត្រាជាចំណូលរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៤ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ..០៦៥.... សហវ.ប្រក.អទច ចុះថ្ងៃទី..២៩... ខែ..កក្កដា.. ឆ្នាំ២០២៤ ស្តីពីការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិច្បាប់ស្តីពីផ្លូវថ្នល់

**បញ្ជីផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិច្បាប់ស្តីពីផ្លូវថ្នល់**

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ផាកពិន័យ (រៀល) |
|---|---|---|---|
| ១ | ជនណាដែលទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍន៍ផ្លូវថ្នល់ថ្មី ដែលមិនបានបំពាក់បរិក្ខារផ្លូវថ្នល់តាមគម្រោងប្លង់សាងសង់ | មាត្រា៥២ | ៥ ០០០ ០០០ រៀល |
| ២ | ជនណាដែលទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍន៍ផ្លូវថ្នល់ថ្មី ដែលបំពាក់បរិក្ខារផ្លូវថ្នល់មិនគ្រប់គ្រាន់តាមគម្រោងប្លង់សាងសង់ និងមិនស្របតាមបទប្បញ្ញត្តិបច្ចេកទេស | មាត្រា៥២ | ២ ០០០ ០០០ រៀល |
| ៣ | ជនណាដែលទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍន៍ផ្លូវថ្នល់ថ្មី ដែលបំពាក់បរិក្ខារផ្លូវថ្នល់គ្រប់គ្រាន់តាមគម្រោងប្លង់សាងសង់ ប៉ុន្តែមិនស្របតាមបទប្បញ្ញត្តិបច្ចេកទេស | មាត្រា៥២ | ១ ០០០ ០០០ រៀល |
| ៤ | នីតិបុគ្គលណាដែលទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍន៍ផ្លូវថ្នល់ថ្មី ដែលមិនបានបំពាក់បរិក្ខារផ្លូវថ្នល់តាមគម្រោងប្លង់សាងសង់ | មាត្រា៥៣ | ១០ ០០០ ០០០ រៀល |
| ៥ | នីតិបុគ្គលណាដែលទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍន៍ផ្លូវថ្នល់ថ្មី ដែលបំពាក់បរិក្ខារផ្លូវថ្នល់មិនគ្រប់គ្រាន់តាមគម្រោងប្លង់សាងសង់ និងមិនស្របតាមបទប្បញ្ញត្តិបច្ចេកទេស | មាត្រា៥៣ | ៥ ០០០ ០០០ រៀល |
| ៦ | នីតិបុគ្គលណាដែលទទួលសិទ្ធិសាងសង់ ឬអភិវឌ្ឍន៍ផ្លូវថ្នល់ថ្មី ដែលបំពាក់បរិក្ខារផ្លូវថ្នល់គ្រប់គ្រាន់តាមគម្រោងប្លង់សាងសង់ ប៉ុន្តែមិនស្របតាមបទប្បញ្ញត្តិបច្ចេកទេស | មាត្រា៥៣ | ២ ០០០ ០០០ រៀល |
| ៧ | ជនណាដែលទទួលសិទ្ធិសាងសង់ ផ្លូវថ្នល់ ផ្លូវប្រសព្វ ផ្លូវប្រសព្វក្នុងលំហ ផ្លូវជាន់គ្នាស្ពានអាកាស ស្ពានរំលង ផ្លូវរូងក្រោមដី ផ្លូវក្រោមទឹក ឬផ្លូវជួបគ្នារវាងផ្លូវថ្នល់ និងផ្លូវអយស្ម័យយាន ដោយមិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសដែលបានកំណត់ក្នុងគម្រោងប្លង់សាងសង់ | មាត្រា៥៤ | ៥ ០០០ ០០០ រៀល |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ផាកពិន័យ (រៀល) |
|---|---|---|---|
| ៨ | នីតិបុគ្គលណាដែលទទួលសិទ្ធិសាងសង់ ផ្លូវថ្នល់ ផ្លូវប្រសព្វ ផ្លូវប្រសព្វក្នុងលំហ ផ្លូវជាន់គ្នាស្ពានអាកាស ស្ពានរំលង ផ្លូវរូងក្រោមដី ផ្លូវក្រោមទឹក ឬផ្លូវជួបគ្នារវាងផ្លូវថ្នល់ និងផ្លូវអយស្ម័យយាន ដោយមិនគោរពតាមបទប្បញ្ញត្តិបច្ចេកទេសដែលបានកំណត់ក្នុងគម្រោងប្លង់សាងសង់ | មាត្រា៥៥ | ១០ ០០០ ០០០ រៀល |
| ៩ | ជនដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ ដែលយកថ្លៃប្រើប្រាស់ផ្លូវថ្នល់ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៦ | ៥ ០០០ ០០០ រៀល |
| ១០ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែជនដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ នៅតែយកថ្លៃប្រើប្រាស់ផ្លូវថ្នល់ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៦ | ១០ ០០០ ០០០ រៀល |
| ១១ | ជនដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ ដែលមិនបានផ្សព្វផ្សាយជាសាធារណៈនូវថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៦ | ២ ០០០ ០០០ រៀល |
| ១២ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែជនដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ នៅតែមិនផ្សព្វផ្សាយជាសាធារណៈនូវថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៦ | ៤ ០០០ ០០០ រៀល |
| ១៣ | ជនដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ដែល មិនព្រមបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមកិច្ចព្រមព្រៀងជាមួយស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៦ | ២ ០០០ ០០០ រៀល |
| ១៤ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែជនដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ នៅតែមិនបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមកិច្ចព្រមព្រៀងជាមួយស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៦ | ៤ ០០០ ០០០ រៀល |
| ១៥ | នីតិបុគ្គលណាដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ ដែលយកថ្លៃប្រើប្រាស់ផ្លូវថ្នល់ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៦ | ១០ ០០០ ០០០ រៀល |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ផាកពិន័យ (រៀល) |
|---|---|---|---|
| ១៦ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែនីតិបុគ្គលដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ នៅតែយកថ្លៃប្រើប្រាស់ផ្លូវថ្នល់ ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៧ | ២០ ០០០ ០០០ រៀល |
| ១៧ | នីតិបុគ្គលណាដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ ដែលមិនបានផ្សព្វផ្សាយជាសាធារណៈនូវថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៧ | ៥ ០០០ ០០០ រៀល |
| ១៨ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែនីតិបុគ្គលដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ នៅតែមិនផ្សព្វផ្សាយជាសាធារណៈនូវថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៧ | ១០ ០០០ ០០០ រៀល |
| ១៩ | នីតិបុគ្គលណាដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ ដែលមិនព្រមបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមកិច្ចព្រមព្រៀងជាមួយស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៧ | ៥ ០០០ ០០០ រៀល |
| ២០ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែនីតិបុគ្គលដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ នៅតែមិនព្រមបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់ ទៅតាមកិច្ចព្រមព្រៀងជាមួយស្ថាប័នមានសមត្ថកិច្ច | មាត្រា៥៧ | ១០ ០០០ ០០០ រៀល |
| ២១ | សម្បទានិក ឬក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ ដែលមិនសហការ ឬរារាំងមន្ត្រីមានសមត្ថកិច្ចដែលបំពេញតួនាទីដូចមានចែងក្នុងមាត្រា១៩នៃច្បាប់ស្តីពីផ្លូវថ្នល់ | មាត្រា៥៨ | ២ ០០០ ០០០ រៀល |
| ២២ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែសម្បទានិក ឬក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ នៅតែមិនសហការ ឬនៅតែរារាំងមន្ត្រីមានសមត្ថកិច្ចដែលបំពេញតួនាទីដូចមានចែងក្នុងមាត្រា១៩នៃច្បាប់ស្តីពីផ្លូវថ្នល់ | មាត្រា៥៨ | ៥ ០០០ ០០០ រៀល |
| ២៣ | នីតិបុគ្គលណាដែលមិនសហការ ឬរារាំងមន្ត្រីមានសមត្ថកិច្ច ដែលបំពេញតួនាទីដូចមានចែងក្នុងមាត្រា១៩នៃច្បាប់ស្តីពីផ្លូវថ្នល់ | មាត្រា៥៩ | ៥ ០០០ ០០០ រៀល |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ផាកពិន័យ (រៀល) |
|---|---|---|---|
| ២៤ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែនីតិបុគ្គលនៅតែមិនសហការ ឬនៅតែរាំងមន្ត្រីមានសមត្ថកិច្ច ដែលបំពេញតួនាទីដូចមានចែងក្នុងមាត្រា១៩នៃច្បាប់ស្តីពីផ្លូវថ្នល់ | មាត្រា៥៩ | ១០ ០០០ ០០០ រៀល |
| ២៥ | ជនណាដែលមិនគោរពតាមការបញ្ជារបស់ភ្នាក់ងារសុវត្ថិភាព ដែលប្រចាំការតាមគោលដៅ ដូចមានចែងក្នុងមាត្រា២៧ នៃច្បាប់ស្តីពីផ្លូវថ្នល់ | មាត្រា៦២ | ១០ ០០០ រៀល |
| ២៦ | ជនណាសាងសង់របារកាត់ទទឹង ឬទួលបន្ថយល្បឿន ឬវត្ថុប្រហាក់ប្រហែល ពីលើផ្លូវថ្នល់ដោយគ្មានការអនុញ្ញាត | មាត្រា៦៣ | ១ ០០០ ០០០ រៀល |
| ២៧ | ជនណាដែលធ្វើកិច្ចការសាធារណការទាំងឡាយនៅក្នុងតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ គែមផ្លូវ និងដីនៅសល់នៃដីចំណីផ្លូវ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ | មាត្រា៦៤ | ៥០០ ០០០ រៀល |
| ២៨ | នីតិបុគ្គលណាដែលធ្វើកិច្ចការសាធារណការទាំងឡាយលើតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ គែមផ្លូវ និងដីនៅសល់នៃដីចំណីផ្លូវ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ | មាត្រា៦៥ | ១ ០០០ ០០០ រៀល |
| ២៩ | ជនណាដែលធ្វើការលើដីចំណីផ្លូវសម្រាប់ធ្វើផ្លូវចេញចូលគេហដ្ឋាន អាគារ រោងចក្រ សហគ្រាស ឬកន្លែងផ្សេងៗដែលជាប់នឹងផ្លូវថ្នល់ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ | មាត្រា៦៦ | ៥០ ០០០ រៀល |
| ៣០ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែជនដែលធ្វើការលើដីចំណីផ្លូវសម្រាប់ធ្វើផ្លូវចេញចូលគេហដ្ឋាន អាគារ រោងចក្រ សហគ្រាស ឬកន្លែងផ្សេងៗដែលជាប់នឹងផ្លូវថ្នល់ នៅតែប្រព្រឹត្តល្មើសជាថ្មីម្តងទៀត | មាត្រា៦៦ | ១០០ ០០០ រៀល |
| ៣១ | ជនណាដែលធ្វើឱ្យផ្លូវថ្នល់រអិល ស្អិត ចាក់គំនរសំណង់ពង្រាយលើផ្លូវថ្នល់ ឬដាក់សម្ភារៈរាយប៉ាយលើផ្លូវថ្នល់និងដាក់តាំងសម្ភារៈ ឬស្លាកសញ្ញាផ្សេងៗធ្វើឱ្យបាំងភ្នែកអ្នកបើកបរ ឬបង្កឧបសគ្គដល់អ្នកថ្មើរជើងក្នុងការធ្វើដំណើរ | មាត្រា៦៧ | ៥០ ០០០ រៀល |

| លេខរៀងបទល្មើស | ប្រភេទបទល្មើស | មាត្រានៃច្បាប់ | កម្រិតទឹកប្រាក់ជាកពិន័យ (រៀល) |
|---|---|---|---|
| ៣២ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែជនដែលធ្វើឱ្យផ្លូវថ្នល់រអិល ស្អិត ចាក់គំនរសំណង់ពង្រាយលើផ្លូវថ្នល់ ឬដាក់សម្ភារៈរាយប៉ាយលើផ្លូវថ្នល់និងដាក់តាំងសម្ភារៈ ឬស្លាកសញ្ញាផ្សេងៗធ្វើឱ្យបាំងភ្នែកអ្នកបើកបរ ឬបង្កឧបសគ្គដល់អ្នកថ្មើរជើងក្នុងការធ្វើដំណើរ នៅតែប្រព្រឹត្តល្មើសជាថ្មីម្តងទៀត | មាត្រា៦៧ | ១០០ ០០០ រៀល |
| ៣៣ | ជនណាដែលផ្លាស់ប្តូរ រុះរើ ចល័ត សរសេរ ឬធ្វើឱ្យខូចប្រយោជន៍ដល់ស្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ របងការពារសុវត្ថិភាព បង្គោលគីឡូម៉ែត្រ សញ្ញាបង្ហាញទិស | មាត្រា៦៨ | ១០០ ០០០ រៀល |
| ៣៤ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែជនដែលផ្លាស់ប្តូរ រុះរើ ចល័ត សរសេរ ឬធ្វើឱ្យខូចប្រយោជន៍ដល់ស្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ របងការពារសុវត្ថិភាព បង្គោលគីឡូម៉ែត្រ សញ្ញាបង្ហាញទិស នៅតែប្រព្រឹត្តល្មើសជាថ្មីម្តងទៀត | មាត្រា៦៨ | ២០០ ០០០ រៀល |
| ៣៥ | ជនណាប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលធ្វើការថែទាំ ឬបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់ដោយគ្មានអាជ្ញាប័ណ្ណ | មាត្រា៦៩ | ៥ ០០០ ០០០ រៀល |
| ៣៦ | ក្នុងករណីធ្លាប់ទទួលរងការពិន័យហើយ ប៉ុន្តែជនដែលប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលធ្វើការថែទាំ ឬបើកមន្ទីរពិសោធវិស័យផ្លូវថ្នល់ដោយគ្មានអាជ្ញាប័ណ្ណ នៅតែប្រព្រឹត្តល្មើសជាថ្មីម្តងទៀត | មាត្រា៦៩ | ១០ ០០០ ០០០ រៀល |
| ៣៧ | ជនណាដែលរៀបចំសកម្មភាព ឬរៀបចំពិធីផ្សេងៗនៅលើដងផ្លូវថ្នល់ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោមជាតិ | មាត្រា៧០ | ១០០ ០០០ រៀល |